អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៦

សេចក្តីប្រកាសព័ត៌មាន
អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការដេញដោលភ័ស្តុតាងលើការចោទប្រកាន់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈ

ចាប់ពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ តទៅ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងធ្វើសវនាការដេញដោលភ័ស្តុតាងលើការចោទប្រកាន់ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈ នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៨ រូប សាក្សីចំនួន ០៣ រូប និង អ្នកជំនាញចំនួន ០២ រូប ត្រូវបានសម្រេចយកមកស្តាប់សក្ខីកម្មនៅក្នុងផ្នែកនេះ ក្នុងការជំនុំ-ជម្រះក្តីលើសំណុំរឿង ០០២/០២ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន ។

យោងតាមដីកាដំណោះស្រាយ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយស្តីពីការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ តាមរយៈមធ្យោបាយចាំបាច់នានា ចាប់ពីមុនឆ្នាំ ១៩៧៥ រហូតដល់យ៉ាងហោចណាស់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដើម្បីសម្រេចឲ្យបាន និង ការពារបដិវត្តន៍សង្គមនិយម។ យោងតាមការចោទប្រកាន់ នៅទូទាំងប្រទេសកម្ពុជា បុរស និង ស្ត្រី ត្រូវបានគេបង្ខំឲ្យរៀបការ នៅក្នុងពិធីរួមគ្នាដែលមានចាប់ពី ០២ ទៅជាង ១០០ គូក្នុងមួយលើកៗ។ តាមការចោទប្រកាន់ដដែល ចារីបានតម្រូវឲ្យអ្នករៀបការទាំងនោះរួមដំណេកដោយបង្ខំ ដែលធ្វើឲ្យជនរងគ្រោះទទួលរងនូវការបំពារបំពានផ្លូវភេទតាមវិធីបង្ខំ ដោយមិនមានការព្រមព្រៀងពីជនរងគ្រោះ។

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៩២ រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៨ រូប និង អ្នកជំនាញចំនួន ០៤រូប ក្នុងរយៈពេលសវនាការចំនួន ២១៦ ថ្ងៃ។ បន្ទាប់ពីបញ្ចប់សវនាការលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការដេញដោលលើភ័ស្តុតាងពាក់ព័ន្ធនឹងអង្គហេតុជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម ហើយចុងក្រោយបំផុត អង្គជំនុំជម្រះនឹងធ្វើសវនាការលើតួនាទីរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះរំពឹងថា សវនាការលើភ័ស្តុតាងនឹងបញ្ចប់នៅចុងឆ្នាំនេះ ហើយសាលក្រមនឹងប្រកាសនៅចុងឆ្នាំ ២០១៧ ខាងមុខ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

លោក ឡាស អូលសិន
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh